# Innocent Passage (ការឆ្លងកាត់ដោយមិនបំពាន)

ការឆ្លងកាត់នេះ ជាការថ្លឹងប្រយោជន៍រវាងសិទ្ធិនៃរដ្ឋជាប់ឆ្នេរសមុទ្រ (coastal State) ដែលគ្រប់គ្រងលើនាវាបរទេសឆ្លងកាត់ និងសេរីភាពនាវាចរ (freedom of navigation)។ នាវារបស់រដ្ឋទាំងអស់ មិនថារបស់រដ្ឋមិនជាប់ឆ្នេរសមុទ្រ (land-locked State) មានសិទ្ធិឆ្លងកាត់សមុទ្រដែនដី (territorial sea)។ ទោះបីជាយ៉ាងនេះក្ដី ការឆ្លងកាត់ប្រភេទនេះ អាចត្រូវបានធ្វើក្នុងដែនទឹកផ្ទៃក្នុង (ពីមុនជាសមុទ្រដែនដី) (មាត្រា៨នៃអនុសញ្ញា UNCLoS១៩៨២)។ គួរឲ្យកត់សំគាល់ថា អាកាសយាន មិនមានសិទ្ធិហោះហើរដោយមិនបំពានលើសមុទ្រដែនដីទេ។វិធានឆ្លងកាត់ដោយមិនបំពាននេះក្លាយជាវិធានទំនៀមទម្លាប់អន្តរជាតិ។

ការឆ្លងកាត់របៀបនេះ ត្រូវជាបន្តនិងឆាប់រហ័សឆ្ពោះទៅគោលដៅ (មិនអាចបង្អង់សំកាំង) ទោះបីជាយ៉ាងនេះក្ដី នាវាអាចផ្អាកដំណើរឆ្លងកាត់ ដោយសារកត្តាប្រធានសក្តិ ឈប់ជួយសង្គ្រោះមនុស្សក្នុងសមុទ្រ។ ការឆ្លងកាត់ដោយមិនបំពាន ដរាបណាមិនប៉ះពាល់ដល់សន្តិភាព ឬសន្តិសុខនៃរដ្ឋជាប់ឆ្នេរ។ សកម្មភាពមួយចំនួន ដូចជា ការគម្រាមប្រើកំលាំង អាចត្រូវបានចាត់ថាជាការឆ្លងការដោយបំពាន។

នាវាមុជទឹក ត្រូវងើបឡើងនៅលើផ្ទៃទឹកក្នុងអំឡុងពេលឆ្លងកាត់។ ដោយឡែក សម្រាប់នាវាចំបាំងតម្រូវឲ្យធ្វើដំណើរក្នុងលក្ខណៈធម្មតា (គ្មានការហ្វឹកសម) ហើយ ត្រូវមានឯកសារពិសេស និងវិធានការប្រុងប្រយ័ត្ន (precautionary measures) ចំពោះនាវាដើរដោយឋាមពលនុយក្លេអ៊ែរ។ រដ្ឋខ្លះទាមទារឲ្យមានការអនុញ្ញាត ជាមុននូវការឆ្លងកាត់ដោយមិនបំពាននូវនាវាចំបាំង ឬដើរដោយឋាមពលនុយក្លេអ៊ែរ។

រដ្ឋជាប់ឆ្នេរមានកាតព្វកិច្ច ដូចជា មិនត្រូវបង្អាក់ ( hamper) ការឆ្លងកាត់ដោយមិនបំពាន ក៏ប៉ុន្តែអាចចាត់វិធានការចាំបាច់មួយចំនួនក្នុងការបង្ការការឆ្លងកាត់ដែលបំពាន។ រដ្ឋជាប់ឆ្នេរ ផ្អែកតាមមូលហេតុសន្តិសុខ អាចផ្អាកជាបណ្ដោះអាសន្ននូវការឆ្លងកាត់មិនបំពានបាន។

ការវាយតម្លៃថា មិនបំពានឬមិន មិនផ្ដោតលើប្រភេទនៃនាវាទេ គឺផ្ដោតលើសកម្មភាពរបស់នាវា។ ក្នុងន័យនេះ ការគ្រាន់តែបំពានច្បាប់រដ្ឋជាប់ឆ្នេរ មិនគ្រប់គ្រាន់ក្នុងការបដិសេធនូវការឆ្លងកាត់។ ជាចុងក្រោយ រដ្ឋជាប់ឆ្នេរ ត្រូវឲ្យសញ្ញាបង្ហាញដល់នាវាដែលឆ្លងកាត់ឲ្យដឹងថា ការឆ្លងកាត់របស់ខ្លួន លែងជាការឆ្លងកាត់ដោយមិនបំពាន ដើម្បីឲ្យនាវានោះ អាចកែសម្រួលមកជាការឆ្លងកាត់ដោយមិនបំពានវិញ។

**UNCLoS, article 19 (Meaning of Innocent Passage)**

1. Passage is innocent so long as it is not prejudicial to the peace, good order or security of the coastal State. Such passage shall take place in conformity with this Convention and with other rules of international law.

2. Passage of a foreign ship shall be considered to be prejudicial to the peace, good order or security of the coastal State if in the territorial sea it engages in any of the following activities:

(a) any threat or use of force against the sovereignty, territorial integrity or political independence of the coastal State, or in any other manner in violation of the principles of international law embodied in the Charter of the United Nations;

(b) any exercise or practice with weapons of any kind;

(c) any act aimed at collecting information to the prejudice of the defence or security of the coastal State;

(d) any act of propaganda aimed at affecting the defence or security of the coastal State;

(e) the launching, landing or taking on board of any aircraft;

(f) the launching, landing or taking on board of any military device;

(g) the loading or unloading of any commodity, currency or person contrary to the customs, fiscal, immigration or sanitary laws and regulations of the coastal State;

(h) any act of willful and serious pollution contrary to this Convention;

(i) any fishing activities;

(j) the carrying out of research or survey activities;

(k) any act aimed at interfering with any systems of communication or any other facilities or installations of the coastal State;

(l) any other activity not having a direct bearing on passage.